ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.......................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីលៀងសាយភោជនប្រចាំឆ្នាំ
នៅសណ្ឋាគារ Sofitel Phnom Penh Phokeethra ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១២

សូមគោរព ៖

- លោកឧកញ៉ា ពុង ឃាវសែ ប្រធានសមាគមធនាគារនៅកម្ពុជា និងជាប្រធានក្រុមប្រឹក្សាភិបាលធនាគារកាណាឌីយ៉ា
- លោក ប៊ុន មន្នី ប្រធានសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងជាអគ្គនាយកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនា លីមីតធីត
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំមានសេចក្ដីសោមនស្សរីករាយជាអនេក ដោយបានចូលរួមពិធីលៀងសាយភោជនប្រចាំឆ្នាំ ដែលបានរៀបចំឡើងដោយសមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងធនាគារជាតិនៃកម្ពុជា នាពេលនេះ។ ពិធីនេះបានក្លាយជាវេទិកាដ៏សំខាន់មួយសម្រាប់គណៈគ្រប់គ្រង-និយោជិតរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងមន្ត្រីធនាគារជាតិនៃកម្ពុជា ពិភាក្សាពីកាលានុវត្តភាពវិនិយោគ ពង្រឹងកិច្ចសហប្រតិបត្តិការ និងសាមគ្គីភាពរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអាជ្ញាធរត្រួតពិនិត្យ ។ កាលពី១០ឆ្នាំមុន ពិធីនេះមានអ្នកចូលរួមតែ ៥០នាក់ប៉ុណ្ណោះ ។ បន្ទាប់មក ចំនួនអ្នកចូលរួមកាន់តែកើនច្រើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ។ ហើយពិធីយើងពេលនេះមានអ្នកចូលរួមជាធនាគារិកមិនតិចជាង ៥០០នាក់ទេ ដែលជាអ្នកគ្រប់គ្រងវិស័យធនាគារ មានទ្រព្យសកម្មសរុបលើសពី ១១ពាន់លានដុល្លារអាមេរិក ស្មើនឹងប្រមាណ ៧០% នៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជា ។

នេះបញ្ជាក់ថា ការងារសមាគមគ្រឹះស្ថានធនាគារយើងកាន់តែរីកចម្រើនរឹងមាំជាលំដាប់ និងបានរួមចំណែកក្នុងការពង្រឹងនិងអភិវឌ្ឍប្រព័ន្ធធនាគារឱ្យរឹងមាំមានសុវត្ថិភាព និងមានផលិតភាព ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដែលបានសហការរៀបចំពិធីនេះឡើងដើម្បីអបអរសាទរចំពោះសមិទ្ធផលនានាដែលសម្រេចបាន និងទិសដៅការងារដែលត្រូវអនុវត្តនៅពេលខាងមុខ ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី!

បច្ចុប្បន្ន វិស័យធនាគារនិងហិរញ្ញវត្ថុកម្ពុជាកំពុងអភិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់ និងត្រូវបានពង្រឹង បន្ទាប់ពីកម្ពុជាបានរងនូវឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុពិភពលោកនៅចុងឆ្នាំ២០០៨ ខណៈពេលដែលទីផ្សារអចលនទ្រព្យនៅស្ងៀម មិនដំណើរការ ។ ទំហំនិងភាពស៊ីជម្រៅនៃវឌ្ឍនភាពនេះ គឺគួរឱ្យកោតសរសើរ ។ គិតត្រឹមរយៈពេល ៩ខែ ក្នុងឆ្នាំ២០១២នេះ ប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារបានកើនឡើងប្រមាណ ២៧,៦៧% បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំមុន ហើយមានអ្នកដាក់ប្រាក់បញ្ញើកើនឡើងប្រមាណ ១,៩លាននាក់ ខណៈដែលឥណទានចំពោះវិស័យឯកជនបានកើនឡើង ៣២,៧៨% ដោយមានអ្នកខ្ចីប្រាក់ចំនួន ១,៦ លាននាក់ ។ ខណៈដែលអាជ្ញាធរនៃប្រទេសក្នុងតំបន់អនុវត្តនូវវិធានការប្រុងប្រយ័ត្ន ដើម្បីពង្រឹងប្រព័ន្ធធនាគារ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជាក៏ចាប់ផ្តើមមានការប្រុងប្រយ័ត្នជាងមុន ក្នុងការគ្រប់គ្រងឥណទាន តាមរយៈនីតិវិធីផ្តល់ឥណទាន ដូចដែលបានឆ្លុះបញ្ចាំងតាមរយៈការធ្លាក់ចុះនៃឥណទានមិនដំណើរការប្រមាណពី ៣,៣២% ទៅ ២,៧៩% ។

ខ្ញុំសូមគាំទ្រចំពោះការអនុវត្តវិធានការប្រុងប្រយ័ត្ននេះតទៅទៀត ។ ការបង្កើតនូវការិយាល័យព័ត៌មានឥណទានកម្ពុជា នឹងក្លាយជាឧបករណ៍បន្ថែមមួយទៀតសម្រាប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងការរួមចំណែកគ្រប់គ្រង និងកាត់បន្ថយហានិភ័យឥណទានរបស់ខ្លួន ។ ទោះបីជាបច្ចុប្បន្ន ការិយាល័យព័ត៌មានឥណទានយើងនៅប្រឈមនឹងបញ្ហាបច្ចេកទេសយ៉ាងណាក៏ដោយ ក៏ការចែករំលែកព័ត៌មានឥណទានត្រូវបានគាំទ្រយ៉ាងខ្លាំង និងទទួលស្គាល់ពីសំណាក់អ្នកប្រើប្រាស់ វិនិយោគិនបរទេស ក៏ដូចជាអង្គការអន្តរជាតិនានា ។ ធនាគារជាតិនៃកម្ពុជានឹងបន្តពិនិត្យលើវឌ្ឍនភាពនៃដំណើរការរបស់ការិយាល័យព័ត៌មានឥណទានកម្ពុជា តាមរយៈការពិនិត្យលើអភិបាលកិច្ច កិច្ចការពារអតិថិជន និងនិរន្តរភាពនៃហិរញ្ញវត្ថុ ។

ម្យ៉ាងទៀតបញ្ហា "Access to finance and financial inclusion" ក្នុងនាមជាអាជ្ញាធរអាណាព្យាបាល ធនាគារជាតិនៃកម្ពុជាបាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការពង្រីកបណ្តាញសេវានិងផលិតផលហិរញ្ញវត្ថុ ដើម្បីឱ្យប្រជាជនទូទៅមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុកាន់តែសម្បូរបែប ។ បច្ចុប្បន្ននេះ ប្រជាជនកម្ពុជាចំនួនតែ ១៣% ប៉ុណ្ណោះ ដែលទទួលបានសេវាហិរញ្ញវត្ថុ ខណៈដែល ៨៩% នៃមីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម (MSME) កំពុងទទួលហិរញ្ញប្បទានសម្រាប់ប្រតិបត្តិការរបស់ខ្លួន តាមរយៈទីផ្សារក្រៅប្រព័ន្ធធនាគារផ្លូវការ ដែលយ៉ាងហោចណាស់ស្មើនឹង ៣,៧ពាន់លានដុល្លារអាមេរិក នៃតម្លៃឱកាសដែលបាត់បង់ យោងតាមរបាយការណ៍មួយរបស់ធនាគារពិភពលោក ។ របាយការណ៍

មួយផ្សេងទៀតរបស់ស្ថាប័ននេះ ក្រោមចំណងជើងថា "ហិរញ្ញវត្ថុវិសមភាពនិងភាពក្រីក្រៈ ការសិក្សាឆ្លងប្រទេស" បានបង្ហាញពីទំនាក់ទំនង (correlation) រវាងលទ្ធភាពទទួលបានហិរញ្ញប្បទាន និងកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍអន្តរការិយកម្មហិរញ្ញវត្ថុ និងការកាត់បន្ថយភាពក្រីក្រ ។ តាមរយៈនេះ បរិមាណដ៏ទាបនៃការទទួលបានសេវាហិរញ្ញវត្ថុនៅកម្ពុជា គឺជាសូចនាករមួយដែលទាមទារឱ្យយើង ទាំងអាជ្ញាធរ ទាំងប្រតិបត្តិករ ត្រូវខិតខំធ្វើបន្តទៅទៀត ។ ខ្ញុំសូមស្នើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបង្កើតគោលនយោបាយនិងនីតិវិធីសមស្រប ដើម្បីផ្តល់លទ្ធភាពឱ្យមីក្រូសហគ្រាស និងសហគ្រាសធុនតូចនិងមធ្យម (MSME) ទទួលបានឥណទានទៅពង្រីកមុខរបរអាជីវកម្មរបស់ខ្លួនកាន់តែប្រសើរថែមទៀត ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី!**

សរុបមក ការអភិវឌ្ឍរីកចម្រើននិងសមិទ្ធផលជាច្រើននៃវិស័យធនាគារ រហូតដល់បច្ចុប្បន្ននេះ កើតឡើងដោយសារភាពអំណោយផលពីកត្តាសន្តិភាព ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជាតិ ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។ ជាទិសដៅធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្ត***យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០*** របស់រាជរដ្ឋាភិបាល ដែលបានកំណត់យ៉ាងច្បាស់នូវផែនទីមគ្គុទ្ទេសក៍ សម្រាប់ការបញ្ជ្រាបសេវាហិរញ្ញវត្ថុ ឱ្យកាន់តែទូលំទូលាយដល់ប្រជាពលរដ្ឋដែលមានចំណូលទាប និងសម្រាប់ជំរុញការប្រើប្រាស់រូបិយវត្ថុជាតិ ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះសមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងក្រុមការងាររៀបចំកម្មវិធីនេះ ដែលបានខិតខំប្រឹងប្រែងធ្វើឱ្យព្រឹត្តិការណ៍នេះកើតឡើង ។ ខ្ញុំសូមឆ្លៀតយកឱកាសនេះ សូមប្រសិទ្ធពរជូនចំពោះឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និងនាងកញ្ញាទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន និងមានជ័យជំនះគ្រប់ភារកិច្ចរៀងៗខ្លួន ។ ខណៈពេលដំណាច់ឆ្នាំនឹងខិតជិតមកដល់ ខ្ញុំសូមជូនពរអស់លោក-លោកស្រី សិរីសួស្តីឆ្នាំថ្មី និងសម្រាប់អស់លោក-លោកស្រី ដែលជាគ្រិស្តបរិស័ទ "Merry Christmas!" ។

**សូមអរគុណ**!